ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៩ លេខ ៤ ខែធ្នូ ២០១៥ តម្លៃ ១.៥០០៛

# គណនេយ្យភាពសង្គម ក្នុងការផ្ដល់សេវាសាធារណៈនៅកម្ពុជា

## សេចក្ដីផ្ដើម

ក្នុងផ្នែកមួយនៃ កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ ២០១៣ បានអនុវត្តផែនការយុទ្ធសាស្ត្រ ស្ដីពី គណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្ត្រនេះ សំដៅកែលំអការផ្ដល់សេវាសាធារណៈ និងពង្រឹងទំនាក់ទំនងរវាងរដ្ឋ នឹងប្រជាជន។ កិច្ចការទាំងនេះវាជាប់ទាក់ទងដល់ការអភិវឌ្ឍក្នុងមូលដ្ឋាន និងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវ។ នៅកម្ពុជាមានការស្រាវជ្រាវតិចតួចណាស់ ស្ដីពីគណនេយ្យភាពសង្គម ក្រៅពីការស្រាវជ្រាវរបស់ Burke and Nil (2004), World Bank (2013), Rodan and Hughes (2012), Norman (2014) និង Babovic and Vukovic (2014)។ ការស្រាវជ្រាវភាគច្រើនត្រូវបានធ្វើឡើងនៅក្នុងដំណាក់កាលដំបូងៗនៃ ការផ្ដួចផ្ដើមគំនិតពង្រឹងគណនេយ្យភាពសង្គមនៅកម្ពុជា។ ការយកចិត្តទុកដាក់លើដំណើរការ គណនេយ្យភាពសង្គម និងប្រសិទ្ធភាពនៃការអនុវត្តគម្រោង ក្នុងការជួយជំរុញសកម្មភាពរួមគ្នារបស់ប្រជាជន និងជះឥទ្ធិពលទៅលើការឆ្លើយតបរបស់រដ្ឋាភិបាល នៅមានតិចតួច។ ការសិក្សានេះ មានគោលដៅចូលរួមចំណែក បំពេញកង្វះខាតដូចលើកឡើងខាងលើ និងផ្ដល់ព័ត៌មាន សម្រាប់ឲ្យមានការរំពឹងទុកប្រាកដនិយម ចំពោះគណនេយ្យភាពសង្គម។



*គណនេយ្យភាពសង្គមក្នុងការផ្ដល់សេវាសាធារណៈ៖ ការគ្រប់គ្រងសំណល់រាវ ភ្នំពេញថ្មី ធ្នូ ២០១៥*

គណនេយ្យភាពសង្គមក្នុងអត្ថបទនេះ សំដៅដល់កិច្ចប្រឹងប្រែងរួមគ្នាជាហូរហែរបស់សង្គម ដើម្បីជំរុញឲ្យមន្ត្រីរាជការទទួលខុសត្រូវលើការសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួន។ គោលដៅនេះត្រូវសម្រេចឡើង តាមរយៈការជំរុញមន្ត្រីរាជការឲ្យឆ្លើយតប ដើម្បីជៀសវាងការខាតបង់ផ្នែកនយោបាយ និងកេរ្តិ៍ឈ្មោះរបស់ខ្លួន (Peruzotti and Smulovitz 2006)។ កន្លងមក មានការប្រើមធ្យោបាយពង្រឹងគណនេយ្យភាពសង្គមផ្សេងៗ រួមមាន ប័ណ្ណដាក់ពិន្ទុលើសេវាសង្គមនៅតាមសហគមន៍ អង្កេតតាមដានចំណាយសាធារណៈ ការធ្វើផែនការថវិកាដោយមានការចូលរួមពីមូលដ្ឋាន វេទិកាសាធារណៈ ការកសាងសមត្ថភាព និងទម្រង់ផ្សេងៗទៀតនៃការចូលរួមរបស់ពលរដ្ឋក្នុងតំបន់។ ដូច្នេះគណនេយ្យភាពសង្គម គឺជាពាក្យរួមមួយ សម្រាប់សំដៅលើវិធីសាស្ត្រជាច្រើនដែលអនុវត្តដោយសង្គមស៊ីវិល ដើម្បីកៀងគរផលប្រយោជន៍ និងសម្លេងរបស់ប្រជាពលរដ្ឋ ដើម្បីមានការទាមទារកាន់តែខ្លាំងដល់មន្ត្រីរាជការ (Goetz and Jenkins 2005; Hirschman 1970)។

អត្ថបទនេះផ្អែកលើ លទ្ធផលសិក្សាស្ដីពីគណនេយ្យភាពសង្គម ចុះក្នុងឯកសារពិភាក្សាលេខ ១០២ ចេញផ្សាយដោយវិទ្យាស្ថាន CDRI (Eng, Vong and Hort 2015)។ ការសិក្សានេះមានគោលបំណងស្វែងយល់ពី ដំណើរការគម្រោងគណនេយ្យ

អត្ថបទនេះរៀបចំដោយ បណ្ឌិត អេង នេត្រា អ្នកស្រាវជ្រាវជាន់ខ្ពស់ វង់ ម៉ាន់ អ្នកស្រាវជ្រាវ និង ហ៊ត ណារី ជំនួយការស្រាវជ្រាវ ផ្នែកអភិបាលកិច្ច នៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា អេង នេត្រា, វង់ ម៉ាន់ និង ហ៊ត ណារី. 2015. “គណនេយ្យភាពសង្គមក្នុងការផ្ដល់សេវាសាធារណៈនៅកម្ពុជា” *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* 19(4): 1-4. ភ្នំពេញ វិទ្យាស្ថាន CDRI។

## មាតិកា

គណនេយ្យភាពសង្គមក្នុងការផ្ដល់សេវាសាធារណៈនៅកម្ពុជា..១
ភាពងាយរងគ្រោះ និងការបន្សាំការប្រែប្រួលអាកាសធាតុ
នៅអាងបឹងទន្លេសាប៖ ដំណើររឿងនៃអាងស្ទឹងចំនួនបី ......៥
ការពិនិត្យស្រាវជ្រាវដោយសង្ខេបពីឧត្តមសិក្សានៅកម្ពុជា .....១៣
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ......................................២៤

ភាពសង្គមនៅកម្ពុជា ហេតុអ្វីវាដំណើរការតាមរបៀបនោះ ហើយបានលទ្ធផលយ៉ាងណាដែរ ជាពិសេស បើធៀបនឹងការរំពឹងទុក ហើយតើវារួមចំណែកបានប៉ុណ្ណា ក្នុងការផ្តល់សិទ្ធិអំណាចដល់ប្រជាជនកម្ពុជាទូទៅ ដើម្បីអាចរួមដៃគ្នា និងជំរុញមន្ត្រីរាជការឲ្យលើកស្ទួយគោលនយោបាយ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាជន និងជួយកែលំអសេវាសាធារណៈ។

ជំនួយគាំទ្រសម្រាប់គណនេយ្យភាពសង្គម ពីសំណាក់ម្ចាស់ជំនួយ និងរដ្ឋាភិបាល ផ្តល់ឱកាសជាច្រើនដល់តួអង្គផ្សេងៗ។ ការសិក្សានេះ ព្យាយាមស្វែងយល់ថា តើវិធីជំរុញ និងអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជាសព្វថ្ងៃ បានផ្តល់ឲ្យប្រជាជនកម្ពុជាទូទៅ ជាពិសេស ជនក្រីក្រ នូវសិទ្ធិអំណាចពិតប្រាកដក្នុងការតាមមើលលើស្ថាប័នរដ្ឋនានា និងលើកសំណើជាសាធារណៈដោយមានប្រសិទ្ធភាព ដែរឬទេ។ ចំណុចទាំងនេះ ត្រូវបានពិនិត្យតាមរយៈករណីសិក្សាស្តីពី គម្រោងគណនេយ្យភាពសង្គមចំនួន ៣ ដែលទាក់ទងនឹងការផ្តល់សេវាសាធារណៈ រួមមាន ការថែទាំសុខភាពបឋម ការត្រួតពិនិត្យសៀវភៅសិក្សានៅតាមសាលារៀន និងការគ្រប់គ្រងទឹកស្អាត និងកាកសំណល់រឹងក្នុងទីប្រជុំជន។

## សេវាគ្រប់គ្រងទឹកស្អាត និងកាកសំណល់រឹងក្នុងទីប្រជុំជន

ករណីសិក្សានេះ ពិនិត្យពីគម្រោងគណនេយ្យភាពសង្គមដែលផ្តួចផ្តើមគំនិត និងផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ ក្នុងការគ្រប់គ្រងទឹកស្អាត និងកាកសំណល់រឹង។ សីលការ ជាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមួយ មានទីតាំងនៅរាជធានីភ្នំពេញ បានចុះកិច្ចសន្យាអនុវត្តគម្រោងនេះ ចាប់ពីខែមីនា ២០១១ ដល់ខែមីនា ២០១៣ ក្នុង ២សង្កាត់ នៅក្រុងតាខ្មៅ ដែលមានចម្ងាយប្រហែល ១២គម ពីរាជធានីភ្នំពេញ។ សង្កាត់ ២ ត្រូវបានជ្រើសរើសធ្វើជាទីតាំងគម្រោង ព្រោះមានស្ថានភាពក្រីក្រជាងគេ និងខ្វះខាតខ្លាំងជាងគេនូវបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងសេវាអនាម័យ។ គម្រោងនេះមានគោលដៅ ពង្រឹងអភិបាលកិច្ច និងប្រជាធិបតេយ្យនៅមូលដ្ឋាន តាមរយៈការប្រើប្រាស់ឧបករណ៍គណនេយ្យភាពសង្គម។

## គណនេយ្យភាពក្នុងការផ្គត់ផ្គង់ទឹកស្អាត និងការគ្រប់គ្រងកាកសំណល់

ការផ្គត់ផ្គង់ទឹកស្អាតនៅរាជធានីភ្នំពេញ និងតំបន់ជុំវិញ ជាការទទួលខុសត្រូវរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលជាទីភ្នាក់ងាររដ្ឋមួយមានស្វ័យភាពក្នុងការគ្រប់គ្រងស្ថាប័ន និងហិរញ្ញវត្ថុរបស់ខ្លួន។ រដ្ឋាករទឹក មានសិទ្ធិសម្រេចលើបញ្ហាបុគ្គលិក វិនិយោគ ការគ្រប់គ្រងហិរញ្ញវត្ថុ និងកម្មវិធីពង្រីកទៅខាងក្រៅ។ បញ្ហាអនាម័យ មានភាពស្មុគស្មាញជាងការផ្គត់ផ្គង់ទឹកស្អាត ព្រោះមានក្រសួងច្រើនចូលពាក់ព័ន្ធ ដែលនាំឲ្យមានវិនិយោគ និងការយកចិត្តទុកដាក់មានកម្រិតពីរដ្ឋាភិបាល។ ការគ្រប់គ្រងកាកសំណល់រឹង ជាការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន។ សេវាប្រមូល និងគ្រប់គ្រងកាកសំណល់រឹង ជាទូទៅអនុវត្តដោយក្រុមហ៊ុនឯកជន តាមរយៈការចុះកិច្ចសន្យាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមិនមានការចូលរួមពីសំណាក់អាជ្ញាធរមូលដ្ឋានទេ។

ក្នុងករណីទាំងពីរនេះ សេចក្តីសម្រេចផ្សេងៗ លើការផ្តល់សេវា តែងធ្វើឡើងដោយតួអង្គនៅថ្នាក់ជាតិ ហើយមានព័ត៌មានត្រឡប់ និងការចូលរួមតិចតួចពីថ្នាក់មូលដ្ឋាន។

## លទ្ធផល

ប្រហែលជាងមួយឆ្នាំក្រោយពេលគម្រោងនេះត្រូវបានបញ្ចប់ លទ្ធភាពរបស់ប្រជាជនក្រីក្រក្នុងការទទួលបានទឹកស្អាត និងសេវាអនាម័យ នៅក្នុងសង្កាត់ទាំងពីរ សឹងតែគ្មានការប្រែប្រួល។ ការសិក្សាដល់កន្លែងបង្ហាញថា នៅឆ្នាំ២០១៣ មានតែ ៣៧គ្រួសារប៉ុណ្ណោះដែលបានប្រើប្រាស់សេវាប្រមូលកាកសំណល់រឹង ហើយសុទ្ធតែនៅក្នុងសង្កាត់ ដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ២។ គ្រួសារក្រីក្រខ្លះដែលរស់នៅតាមដងផ្លូវក្រាលកៅស៊ូ នៅក្នុងសង្កាត់មួយ បានតភ្ជាប់បណ្តាញទឹកស្អាត។ ពួកគាត់បានប្រើប្រាស់ទឹកស្អាត មិនមែនដោយសារគម្រោងគណនេយ្យភាពសង្គមនោះទេ ព្រោះមិនមានអ្នកផ្តល់សម្ភាសន៍ណាម្នាក់បានដឹងពីសកម្មភាពរបស់អង្គការសីលការឡើយ ប៉ុន្តែដោយសារការប្រើប្រាស់បណ្តាញខ្សែខ្នងប្រកបដោយប្រសិទ្ធភាព។

ក្នុងសង្កាត់ទាំងពីរនេះ គម្រោងសម្រេចបានជោគជ័យតិចតួចក្នុងការផ្តល់សិទ្ធិអំណាចដល់អ្នកភូមិ។ គណៈកម្មការនានាដែលរៀបចំបានហើយនៅក្នុងសង្កាត់ និងដែលអង្គការសីលការរំពឹងថា អាចក្លាយជាតួអង្គសំខាន់ក្នុងការដាក់សំណើដល់មន្ត្រីនានា ដើម្បីឲ្យមានសេវាល្អជាងមុននោះ បានរលាយបាត់អស់ភ្លាមបន្ទាប់ពីគម្រោងបានចប់នៅដើមឆ្នាំ២០១៣។ អ្នកតំណាងមួយចំនួននិយាយថា ជំនាញទទួលបានពីគម្រោង អាចមានប្រយោជន៍ខ្លាំង ប៉ុន្តែពួកគេមិនអាចប្រើប្រាស់វាបាន ព្រោះនៅខ្លាចអាជ្ញាធរ ហើយម្យ៉ាងទៀត ការចូលរួមរបស់ពួកគេនៅក្នុងវេទិកាសាធារណៈមិនបានជំរុញឲ្យមានការឆ្លើយតបពិតៗ ពីមន្ត្រីរាជការឡើយ។ លទ្ធផលសិក្សាបង្ហាញថា មន្ត្រីរាជការមិនសូវផុសផុលចង់ធ្វើការក្នុងគម្រោងនេះជាមួយអង្គការសីលការទេ។ ទាំងមន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវា ដែលបានឆ្លើយសម្ភាសក្នុងការសិក្សានេះ នៅតែរារែកក្នុងការទទួលយកសំណើ និងការរិះគន់ពីប្រជាពលរដ្ឋ និងអង្គការសីលការ។

## ការគ្រប់គ្រងសៀវភៅសិក្សានៅសាលារៀន

វិទ្យាស្ថានខ្មែរសម្រាប់អភិវឌ្ឍន៍ជាតិ (KIND) ក្នុងកិច្ចសហការជាមួយ សម្ព័ន្ធគណនេយ្យភាពសង្គមអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានអនុវត្តគម្រោងគណនេយ្យភាពសង្គមមួយ ហៅថា "ព័ត៌មានត្រឡប់សម្រាប់កែលំអគុណភាពអប់រំ" ពីឆ្នាំ២០១២ ដល់ ២០១៤ ដោយទទួលបានមូលនិធិពីគម្រោង USAID-Building Bridges for Better Spending in Southeast Asia។ ករណីសិក្សានេះ ពិនិត្យពីគម្រោងតាមដានសៀវភៅសិក្សា ដោយផ្តោតលើការរួមចំណែករបស់គម្រោង ក្នុងការផ្តល់សិទ្ធិអំណាចដល់មាតាបិតា និងសិស្សានុសិស្ស នៅក្នុងទំនាក់ទំនងជាមួយ

សាលារៀន និងមន្ត្រីផ្នែកអប់រំ ដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរក្នុងការផ្តល់សេវា។

## គណនេយ្យភាពក្នុងផ្នែកអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា ទទួលខុសត្រូវលើប្រព័ន្ធអប់រំ គុណភាព គោលនយោបាយ និងបទបញ្ញត្តិអប់រំ ជាទូទៅ។ នៅក្រោមឱវាទក្រសួងអប់រំ មានមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក។ ដោយឡែក ការិយាល័យអប់រំស្រុកដើរតួនាទីសំខាន់ណាស់ ព្រោះធ្វើការដោយផ្ទាល់ជាមួយសាលារៀន ក្នុងការអនុវត្តតាមគោលនយោបាយ ធ្វើការត្រួតពិនិត្យ និងផ្តល់ជំនួយគាំទ្រផ្នែកបច្ចេកទេស។

ទោះបីមានកិច្ចប្រឹងប្រែងផ្ទេរមុខងារ និងការទទួលខុសត្រូវចម្បងៗក្នុងវិស័យអប់រំក្តីការសម្រេចចិត្តនៅមានលក្ខណៈមជ្ឈការខ្លាំង។ ព័ត៌មានគ្រឡប់ និងការចូលរួមរបស់ប្រជាពលរដ្ឋ ត្រូវបានរំពឹងថា នឹងត្រូវធ្វើឡើងតាមរយៈគណៈកម្មការទ្រទ្រង់សាលា។ គណៈកម្មការនេះ ត្រូវបានរំពឹងថា នឹងធ្វើការត្រួតពិនិត្យលើសកម្មភាព ថវិកា និងគុណភាព ហើយក៏មានសិទ្ធិអំណាចក្នុងការអនុម័តផែនការអភិវឌ្ឍន៍សាលាដែរ នៅមុនពេលសាលារៀនបញ្ជូនផែនការនោះទៅថ្នាក់លើ។ ក្នុងការអនុវត្តជាក់ស្តែង គណៈកម្មការសាលា កម្រមានការពិភាក្សាពីបញ្ហាសំខាន់ៗទាក់ទងដល់កម្មវិធីសិក្សា បុគ្គលិក ការគ្រប់គ្រងថវិកា និងការត្រួតពិនិត្យគុណភាពណាស់[១] ។

## លទ្ធផល

តាំងពីចាប់អនុវត្តភ្លាម គម្រោងនេះហាក់ហុចផលបានយ៉ាងច្រើន។ ប្រធានអង្គការ KIND អះអាងថា ស្ថាប័នខ្លួនបានជំរុញឲ្យមាន សកម្មភាពផ្នែកគោលនយោបាយមួយចំនួនរបស់ក្រសួងអប់រំ ក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីថ្មី។ ដោយផ្អែកលើអង្កេតតាមដានចំណាយសាធារណៈ និងប័ណ្ណរបាយការណ៍ប្រជាជន លោករដ្ឋមន្ត្រី បានធ្វើការផ្លាស់ប្តូរពីរយ៉ាង។ ទី១ ក្រសួងបានចេញសេចក្តីព្រមាន ឲ្យបញ្ឈប់ការលក់សៀវភៅសិក្សារបស់រដ្ឋដោយខុសច្បាប់នៅលើទីផ្សារ (MOEYS 2014)។ ទី២ ក្រសួងបានបង្កើតក្រុមការងារមួយ ដើម្បីគ្រប់គ្រងការរៀបរៀងសៀវភៅសិក្សា និងពង្រឹងការបែងចែក និងប្រើប្រាស់សៀវភៅសិក្សានៅគ្រប់សាលារៀន។ ទោះយ៉ាងនេះក្តី គេមិនច្បាស់ទេថា តើវិធានការទាំងនេះមានប្រសិទ្ធភាពដល់កម្រិតណា ព្រោះ មន្ត្រីថ្នាក់ក្រោមៗមានទឹកចិត្តខ្សោយណាស់ក្នុងការអនុវត្តតាម និងចូលរួមក្នុងគម្រោងនេះ។

ការផ្តល់សិទ្ធិអំណាចដល់សិស្សានុសិស្ស និងមាតាបិតា ក្នុងការពិនិត្យតាមដានលើដំណើរការរបស់សាលា ជាទិដ្ឋភាពដ៏សំខាន់មួយនៃគម្រោងនេះ។ លទ្ធផលសម្ភាសន៍ជាមួយអ្នកចូលរួម និងអ្នកមិនបានចូលរួមក្នុងគម្រោង បង្ហាញថា ពួកគេចាប់អារម្មណ៍ខ្លាំង ចង់ចូលរួមក្នុងសកម្មភាពគណនេយ្យភាពសង្គម និងចង់ឲ្យគម្រោងនេះ នាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅតាមសាលារៀន។ ចំណាប់អារម្មណ៍នេះ ឆ្លុះឲ្យឃើញថា ពួកគេបានដឹងពីសិទ្ធិក្នុងការទទួលបានការអប់រំដោយឥតគិតថ្លៃ និងកាតព្វកិច្ចរបស់រដ្ឋ។ ទោះបីពួកគេមានចិត្តផុសផុលដូច្នេះក្តី ក៏នៅតែមានការរារែកខ្លាំងក្នុងការបង្ហាញពីការមិនពេញចិត្តជាមួយសាលារៀន នៅក្នុងអង្គប្រជុំជាសាធារណៈ ព្រោះខ្លាចក្លាយខ្លួនជាមុខសញ្ញា ឬរងការសើចចំអកពីមន្ត្រីនៅសាលា និងមន្ត្រីថ្នាក់ខ្ពស់ផ្សេងទៀត។

បទពិសោធន៍យូរឆ្នាំរបស់មន្ត្រីអប់រំ ក្នុងការធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ផ្តល់នូវបរិយាកាសអំណោយផលសម្រាប់ អង្គការ KIND ក្នុងការអនុវត្តគម្រោងគណនេយ្យភាពសង្គម បើធៀបនឹងគម្រោងនៅក្នុងវិស័យផ្សេងទៀត។ ប៉ុន្តែ ទោះបីមានសហប្រតិបត្តិការល្អ ពីសំណាក់មន្ត្រីថ្នាក់ជាតិមួយចំនួននៅឯក្រសួងក៏ដោយ ក៏តួអង្គដទៃទៀតនៅក្នុងក្រសួង ដូចជា គ្រឹះស្ថានបោះពុម្ពផ្សាយនិងចែកចាយ និងស្ថាប័នក្រោមឱវាទក្រសួង មិនសូវចង់រួមសហប្រតិបត្តិការឡើយ។ មន្ត្រីទាំងនោះ នៅមានអារម្មណ៍មិនទុកចិត្តខ្លាំងចំពោះ អង្គការមិនមែនរដ្ឋាភិបាល។ លទ្ធផលសម្ភាសន៍ជាមួយមន្ត្រីស្រុក និងនាយកសាលា បង្ហាញថា ពួកគេមិនចាប់អារម្មណ៍ធ្វើការជាមួយមន្ត្រី អង្គការ KIND នៅក្នុងគម្រោងនេះទេ ហើយប្រាប់ថា ខ្លួនធ្វើតាមតែការបង្គាប់ពីក្រសួងប៉ុណ្ណោះ។

## ប័ណ្ណពិន្ទុសហគមន៍ និងការថែទាំសុខភាពក្នុងមូលដ្ឋាន

ក្នុងករណីសិក្សានេះ គេបានពិនិត្យពីការផ្លាស់ប្តូរនៅក្នុងសេវាសុខាភិបាល ដោយផ្អែកលើលទ្ធផលទទួលបានពី គម្រោងប័ណ្ណពិន្ទុសហគមន៍សម្រាប់សេវាសុខាភិបាល។ គម្រោងនេះទទួលបានមូលនិធិពីធនាគារពិភពលោក ហើយត្រូវបានអនុវត្តនៅឆ្នាំ ២០១២ ដោយ អង្គការព្រះពុទ្ធសាសនាដើម្បីសុខភាព នៅក្នុង ២០មណ្ឌលសុខភាព ក្នុងស្រុកប្រតិបត្តិគិរីវង្ស ខេត្តតាកែវ។ សម្រាប់ករណីសិក្សានេះ គេបានជ្រើសយកមណ្ឌលសុខភាពជីខ្មារ ដែលគ្របដណ្តប់លើបីឃុំគឺ ជីខ្មារ ស្មោង និង ត្រឡាច។ ឃុំទាំងបី មាន ២៥ភូមិ និងប្រជាជនសរុបជាង ១៦០.០០០នាក់ ដែលភាគច្រើនលើសលុបជាកសិករដាំស្រូវ។

## គណនេយ្យភាពក្នុងការថែទាំសុខភាពបឋម

ដោយគិតគូរពីបញ្ហាគណនេយ្យភាព ក្រសួងសុខាភិបាលបានបង្កើតរចនាសម្ព័ន្ធសម្រាប់ការចូលរួមមួយ ដែលរួមមាន ក្រុមទ្រទ្រង់សុខភាពភូមិ (VHSGs) និង គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព(HCMCs)។លើសពីនេះទៀតមណ្ឌលសុខភាពនីមួយៗ មានដាក់ប្រអប់ទទួលបណ្តឹងតវ៉ាមួយ (World Bank 2013)។ រចនាសម្ព័ន្ធនេះ គេបង្កើតឡើងដើម្បីជំរុញគណនេយ្យភាពពីលើចុះក្រោមនៃមណ្ឌលសុខភាព (Ministry of Health 2008, ៩)។ ទោះយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង មានជួបឧបសគ្គ និងជោគជ័យមួយចំនួន។ ប្រអប់ទទួលបណ្តឹងតវ៉ា កម្រមានការប្រើប្រាស់ណាស់ ហើយកត្តារារាំង រួមមាន អនក្ខរកម្ម កង្វះការយល់ដឹង និងការភ័យខ្លាចគេរកឃើញអត្តសញ្ញាណ

[១] សម្រាប់ការវិភាគលំអិតពីគណៈកម្មការទ្រទ្រង់សាលា សូមមើល World Bank (2013) Voice, Choice and Decision ។

(World Bank 2013, 35)។ VHSG ក៏មានការប្រើប្រាស់មិនពេញលេញដែរ។ ការសិក្សារបស់ World Bank (2013) បានកំណត់ថា បញ្ហានេះបណ្តាលមកពីការយល់ឃើញថា VHSGs ក៏ជាផ្នែកមួយរបស់មណ្ឌលសុខភាពដែរ។ ក្នុងករណីមានបណ្តឹងត៉ាវ ពីអ្នកប្រើប្រាស់សេវា បណ្តឹងទាំងនោះត្រូវបានយកមកពិភាក្សានៅក្នុងអង្គប្រជុំ HCMC។ សកម្មភាពបន្ទាប់ គឺអាចរួមមាន ការពិនិត្យតាមដានបន្តទៀត លើបុគ្គលិកមណ្ឌលសុខភាពដែលជាប់ពាក់ព័ន្ធក្នុងបណ្តឹង និងមានអន្តរាគមន៍របស់ក្រុមប្រឹក្សាឃុំ ដែលជាកត្តានាំឲ្យមានឥរិយាបថរួសរាយរាក់ទាក់ និងសេវាប្រសើរជាងមុន (World Bank 2013, 37)។ ប៉ុន្តែគួរឲ្យស្តាយដោយ ការសិក្សារបស់ World Bank (2013) បង្ហាញថា HCMC មិនសូវឃើញមាន ប្រើសិទ្ធិអំណាចម៉ឺងម៉ាត់របស់ខ្លួនឲ្យបានច្រើនទេ។

## លទ្ធផល

គម្រោងនេះ សំដៅជួយពង្រឹងគុណភាពសេវា និងការថែទាំសុខភាពនៅតាមមណ្ឌលសុខភាព ហើយជាទូទៅបានទទួលជោគជ័យច្រើន។ របាយការណ៍ពិនិត្យតាមដានរបស់អង្គការព្រះពុទ្ធសាសនាដើម្បីសុខភាព បង្ហាញថា ផែនការសកម្មភាពដែលផ្អែកលើប័ណ្ណពិន្ទុសហគមន៍ គឺភាគច្រើនត្រូវបានអនុវត្តដោយជោគជ័យ។ នៅមណ្ឌលសុខភាព ជីខារ គេបានតម្លើងអណ្តូងស្នប់មួយសម្រាប់ផ្គត់ផ្គង់ទឹកដល់បន្ទប់អនាម័យ ហើយបញ្ហាកន្លែងបោះចោលកាកសំណល់ផ្នែកវេជ្ជសាស្ត្រ ត្រូវបានដោះស្រាយមួយភាគ។ បញ្ហាទាក់ទងនឹង ឥរិយាបថរបស់បុគ្គលិកមណ្ឌលសុខភាព ម៉ោងធ្វើការ និងការពិនិត្យជំងឺ បានលើកមកដោះស្រាយក្នុងការប្រជុំផ្ទៃក្នុង ហើយបានឈានទៅធ្វើឲ្យប្រសើរឡើងនូវបញ្ហាទាំងអស់នេះ។

ទាំងមន្ត្រីរាជការ និងអ្នកផ្តល់សេវា បានបង្ហាញចំណាប់អារម្មណ៍ វិជ្ជមាន និងឥរិយាបថស្វាគមន៍។ បុគ្គលិកស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព យល់ថា ប័ណ្ណពិន្ទុសហគមន៍ បានផ្តល់ជាឱកាសដ៏មានប្រយោជន៍ដើម្បីបានដឹងពីមតិសាធារណៈ និងកង្វះខាតផ្នែកសេវា ហើយពួកគេបង្ហាញនូវឆន្ទៈត្រៀមអនុវត្តវិធានការកែតម្រូវផ្សេងៗ។ ឥរិយាបថនេះ គឺជាលទ្ធផលនៃការគាំទ្រនៅក្នុងសិក្ខាសាលាថ្នាក់ជាតិមួយ ដែលរដ្ឋលេខាធិការក្រសួងសុខាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល បានមកចូលរួម នៅមុនពេលគម្រោងចាប់អនុវត្ត ដើម្បីបណ្តុះគំនិតធ្វើការសម្រេចចិត្តរួមគ្នាលើការអនុវត្តគម្រោង។

ការផ្តល់សេវាសម្រេចបានលទ្ធផលល្អក៏ពិតមែន ប៉ុន្តែការផ្តល់សិទ្ធិអំណាចមិនទាន់ចេញជារូបរាងទេ។ នៅពេលចាប់ផ្តើមដំណើរការប័ណ្ណពិន្ទុសហគមន៍ អ្នកសម្របសម្រួលគម្រោង បានបញ្ជាក់ថា ក្រុមការងារពិបាកនឹងបញ្ចុះបញ្ចូលអ្នកភូមិឲ្យចូលរួមក្នុងការប្រជុំតាមភូមិ ដោយសារពួកគេជាប់រវល់ ឬក៏មិនចាប់អារម្មណ៍តែម្តង។ អ្នកចូលរួមម្នាក់ជាអ្នកភូមិដែលសឹងតែមិនអាចរកនឹកឃើញពីបទពិសោធន៍នៃការចូលរួមនោះ បានបញ្ជាក់ថា អ្នកដែលជាប់រវល់មិនបានទៅប្រជុំទេ ប៉ុន្តែអ្នកទំនេរនៅផ្ទះ តែងតែទៅតាមការអញ្ជើញ ទោះបីចាប់អារម្មណ៍ ឬមិនចាប់អារម្មណ៍ក្តី។ ចំណុចនេះមានន័យថា ប្រជាជនទៅចូលរួមប្រជុំអំពីប័ណ្ណពិន្ទុសហគមន៍ មិនមែនដោយសារចង់បញ្ចេញមតិអំពីសេវាសុខភាពនោះទេ ប៉ុន្តែដើម្បីគោរពតាមការកោះអញ្ជើញរបស់អាជ្ញាធរ និងទម្លាប់សង្គមតែប៉ុណ្ណោះ។

## ផលពាក់ព័ន្ធផ្នែកគោលនយោបាយ

ការសិក្សានេះ ពិនិត្យលើគម្រោងគណនេយ្យភាពសង្គមក្នុងការផ្តល់សេវាសាធារណៈចំនួន៣ ដើម្បីពន្យល់ពីដំណើរការគណនេយ្យសង្គម នៅកម្ពុជា និងកំណត់ពីកត្តាជាក់លាក់ដែលជំរុញ ឬបង្អាក់ដំណើរការទាំងនេះ។ ជាលទ្ធផល ក្រុមស្រាវជ្រាវរកឃើញថា គម្រោងទាំងនេះមិនបានរួមចំណែកជំរុញឲ្យប្រជាពលរដ្ឋ ចូលរួមខ្លាំងជាងមុន នៅក្នុងអភិបាលកិច្ចសេវាសាធារណៈ ឬក៏ជួយកែលំអទំនាក់ទំនងរវាង រដ្ឋាភិបាល នឹងអង្គការមិនមែនរដ្ឋាភិបាលទេ ប៉ុន្តែគេបានរកឃើញ ការល្អប្រសើរឡើងខ្លះៗក្នុងការផ្តល់សេវាសាធារណៈ។

ចំណុចសំខាន់សម្រាប់ផ្នែកគោលនយោបាយ បានពីការសិក្សានេះ គឺ ការពង្រឹងឥទ្ធិពលនៃគម្រោងគណនេយ្យភាពសង្គមនៅកម្ពុជា ទាមទារឲ្យមានការលុបបំបាត់បញ្ហាមួយចំនួន ដែលបានលើកឡើងនៅក្នុងករណីសិក្សាទាំងបី មានដូចជា ភាពរារែករបស់ប្រជាពលរដ្ឋក្នុងការទាមទារឲ្យមានការកែលំអ និងរិះគន់លើការផ្តល់សេវាសាធារណៈ ដោយសារខ្លាចមានការស្តីបន្ទោស និង កង្វះចំណាប់អារម្មណ៍ពីសំណាក់អ្នកផ្តល់សេវា ក្នុងការធ្វើអន្តរាគមន៍ផ្សេងៗ។

ចេញពីការសិក្សានេះ គេអាចទាញយកគំនិតមួយចំនួនដើម្បីប្រើប្រាស់នៅក្នុងការរចនារៀបចំ និងការអនុវត្តគម្រោងគណនេយ្យភាពនៅកម្ពុជា នៅពេលអនាគត។

- អង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើការងារនៅតាមមូលដ្ឋានឲ្យបានច្រើនថែមទៀត មុនពេលចាប់អនុវត្តគម្រោងគណនេយ្យភាព ដើម្បីធានាឲ្យមានការចូលរួមពីបុគ្គលមានសមត្ថភាព និងអំណាចសមស្របសម្រាប់គម្រោង។
- អ្នកផ្តល់មូលនិធិសម្រាប់គម្រោង ត្រូវធ្វើការពិនិត្យតាមដានជាទៀងទាត់ ដើម្បីធានាឲ្យមានការចូលរួមពីគ្រប់ភាគី ជាពិសេស ពី អ្នកភូមិដែលមិនមានទំនាក់ទំនងផ្ទាល់ជាមួយអាជ្ញាធរមូលដ្ឋាន ក្រុមប្រជាជនខ្វះសិទ្ធិអំណាច និងអ្នកមាននិន្នាការនយោបាយខុសពីអាជ្ញាធរមូលដ្ឋាន និងគាំទ្រមតិប្រឆាំង។
- សង្គមស៊ីវិល និងម្ចាស់ជំនួយ ធ្វើការវិភាគតាមវិស័យ ដើម្បីស្វែងយល់ថា តើមន្ត្រីរាជការទទួលយកគោលការណ៍គណនេយ្យភាពសង្គម តាំងពីដើមដំបូងដែរឬទេ។ កត្តានេះសំខាន់ណាស់ ព្រោះវាជះឥទ្ធិពលលើលទ្ធផលគម្រោងគណនេយ្យភាពសង្គម ហើយក៏ប៉ះពាល់ដល់ការផ្តល់សិទ្ធិអំណាចដល់អ្នកភូមិ និងទឹកចិត្តរបស់ពួកគេក្នុងការចូលរួមក្នុងគម្រោង។
- ការអនុវត្តគម្រោងគណនេយ្យភាពនៅមូលដ្ឋាន នៅមុនពេលបោះឆ្នោត ជាវិធីល្អមួយ ព្រោះរដ្ឋាភិបាលច្រើនតែទទួលយកមតិយោបល់ និងឆ្លើយតបទៅនឹងសំណើពីថ្នាក់មូលដ្ឋាន។

*តទៅទំព័រ ២៣*

សហគមន៍មូលដ្ឋាន ទាក់ទងនឹងការសាងសង់ និងប្រតិបត្តិការទំនប់វារីអគ្គិសនី។

អ្នកស្រាវជ្រាវពីររូប បានធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវរបស់ខ្លួន នៅក្នុងសន្និសីទអន្តរជាតិចំនួនពីរ។ លោក វង់ ម៉ាន់ បានធ្វើបទបង្ហាញមួយស្ដីពី "ទំនួលខុសត្រូវដោយមិនមានគណនេយ្យភាព៖ ករណីសិក្សាពីគណនេយ្យភាពផ្នែកសង្គមនៅកម្ពុជា" នៅក្នុងសន្និសីទអន្តរជាតិស្ដីពី របបប្រជាធិបតេយ្យ និងគណនេយ្យភាព នៅខេត្ត Surabaya ប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី១០ វិច្ឆិកា ២០១៥។ បណ្ឌិត អេង នេត្រា អ្នកស្រាវជ្រាវ និងប្រធានផ្នែកអភិបាលកិច្ច បានធ្វើបទបង្ហាញមួយ ស្ដីពី "គណនេយ្យភាពផ្នែកសង្គម និងកំណែទម្រង់វិស័យអប់រំនៅកម្ពុជា" នៅក្នុងសិក្ខាសាលាស្ដីពី សេដ្ឋកិច្ចនយោបាយនៃប្រជាជនក្រីក្រ នៅឯសាកលវិទ្យាល័យ Birmingham នៃប្រទេសអង់គ្លេស នៅថ្ងៃទី២ តុលា ២០១៥។

ជំនួយការស្រាវជ្រាវថ្មីពីររូប បានចូលរួមក្នុងក្រុមស្រាវជ្រាវផ្នែកអភិបាលកិច្ច គឺ លោក ហុក គីមហ៊ាន ដែលទទួលបានបរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រនយោបាយ និងទស្សនវិជ្ជា ពីមហាវិទ្យាល័យ Middlebury សហរដ្ឋអាមេរិក និង លោកស្រី ហាវ ហ៊ុចហុង ដែលបានទទួល បរិញ្ញាប័ត្រផ្នែកសង្គមវិជ្ជា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## ផ្នែកសុខភាព

របាយការណ៍ស្ដីពី *ការបញ្ជូនស្ត្រីសម្រាលកូននៅក្នុងប្រព័ន្ធសុខាភិបាលកម្ពុជា* ដែលជាគម្រោងរួមគ្នា ជាមួយមជ្ឈមណ្ឌលនូហ្វៀលសម្រាប់ការអភិវឌ្ឍ និងសុខភាពអន្តរជាតិ (Nuffield Centre for International Health and Development) និងសាកលវិទ្យាល័យ Leeds បានទទួលការពេញចិត្តច្រើន។ របាយការណ៍បីទៀត បានបញ្ជូនទៅសុំការជួយមតិ គឺមានរបាយការណ៍សំយោគនៃការស្រាវជ្រាវរបស់ CDRI លើពលកម្មកុមារនៅក្រោមគម្រោង *ការលុបបំបាត់ការកេងប្រវ័ញ្ចពលកម្មកុមារ តាមរយៈការអប់រំនិងការលើកស្ទួយជីវភាព (EXCEL)*, របាយការណ៍ស្រេចបាច់លើ*ការស្រាវជ្រាវពីអ្នកដឹកនាំមតិមហាជន លើការផ្ដល់អាហារឲ្យទារកនិងកុមារតូចៗ (IYCF)* និងរបាយការណ៍ពី *ការពិនិត្យផ្ទៀងផ្ទាត់លើលទ្ធផលផ្នែកអនាម័យនៅទីជនបទ*។

ដោយផ្អែកលើការប្រជុំតុមូលផ្នែកគោលនយោបាយ ស្ដីពី លក្ខណៈវិជ្ជាជីវៈក្នុងផ្នែកវេជ្ជសាស្ត្រនៅកម្ពុជា៖ បញ្ហាចោទ និងមធ្យោបាយឈានទៅមុខ ដែលសហការរៀបចំឡើងដោយវិទ្យាស្ថាន CDRI និងវិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) កាលពីខែកញ្ញា អ្នកស្រាវជ្រាវផ្នែកសុខភាព កំពុងរៀបចំសំណើធ្វើការស្រាវជ្រាវមួយ ដើម្បីជំរុញសកម្មភាព និងកិច្ចសន្ទនាផ្នែកគោលនយោបាយស្ដីពី *លក្ខណៈសម្បត្តិនៃគ្រូពេទ្យល្អ*។ គម្រោងនេះ សំដៅផ្ដល់ព័ត៌មាន និងជួយលើកស្ទួយសីលធម៌ និងលក្ខណៈវិជ្ជាជីវៈ ក្នុងចំណោមអ្នកអនុវត្ត និងនិស្សិតផ្នែកវេជ្ជសាស្ត្រ។ គោលដៅចម្បងៗត្រូវសម្រេចឲ្យបាន រួមមាន ការកសាងសមត្ថភាពសំខាន់ៗ តាមរយៈសិក្ខាសាលាបណ្ដុះបណ្ដាល ការបង្កើតកម្មវិធីសិក្សាស្នូលប្រកបដោយគុណភាព និងសៀវភៅសិក្សាសម្រាប់និស្សិតពេទ្យ និងអ្នកថែទាំសុខភាព និងការចូលរួមធ្វើកំណែទម្រង់វិស័យសុខាភិបាល ឲ្យបានល្អ ដើម្បីស្ដារទំនុកចិត្តរវាងអ្នកទទួល នឹងអ្នកផ្ដល់សេវាថែទាំសុខភាព ទាំងក្នុងវិស័យសាធារណៈ និងឯកជន។

ដោយមានភាពជាដៃគូជាមួយ Sida និងជំនួយគាំទ្របន្ថែមពីដៃគូផ្សេងទៀត ផ្នែកសុខភាពគ្រោងចាប់ផ្ដើមនៅ ខែកក្កដា ២០១៦ នូវ ការស្រាវជ្រាវដើម្បីផ្ដល់លទ្ធផលជួយគាំទ្រដល់ផែនការយុទ្ធសាស្ត្រសុខាភិបាលថ្មី (HSP3) និងរបៀបវារៈកំណែទម្រង់ វិស័យសុខាភិបាល និងអាទិភាពនានាទៀត។ វេទិកាអ្នកស្រាវជ្រាវផ្នែកសុខាភិបាលនៅកម្ពុជា នៅ ខែវិច្ឆិកា ស្ដីពី ការធ្វើផែនទី និងធ្វើផែនការសម្រាប់ការស្រាវជ្រាវពី ប្រព័ន្ធសុខាភិបាលនៅកម្ពុជា បានរកឃើញប្រធានបទធំៗ ៦ ដើម្បីបង្ហាញពីអាទិភាពនានា ក្នុងកំណែទម្រង់គោលនយោបាយសុខាភិបាល។ ប្រធានបទ និងសកម្មភាពស្រាវជ្រាវផ្សេងៗទៀត នឹងកំណត់ឡើង តាមការពិគ្រោះយោបល់ជាមួយ Sida និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្រោយពេលចាប់អនុវត្ត HSP3 ។

---

*តពីទំព័រ ៤* **គណនេយ្យភាពសង្គម**...

## ឯកសារយោង

Babovic, Marija, and DaniloVukovic. 2014. *Social Accountability in Cambodia.* Justice and Security Research Programme Paper 19. London: London School of Economics.

Burke, Adam, and Vanna Nil. 2004. *Options for Increasing Social Accountability in Cambodia*. Phnom Penh: DFID and World Bank.

Eng Netra, Vong Mun and Hort Navy. 2015. *Social Accountability in Service Delivery in Cambodia*, Working Paper 102, CDRI: Phnom Penh.

Goetz, Anne Marie, and Rob Jenkins. 2005. *Reinventing Accountability: Making Democracy Work for Human Development.* New York: Palgrave Macmillan.

Hirschman, Albert O. 1970. *Exit, Voice, and Loyalty: Responses to Decline in Firms, Organisations and States.* Cambridge: Harvard University Press.

Malena, Carmen, Reiner Forster and Janmejay Singh. 2004. *Social Accountability: An Introduction to the Concept and Emerging Practice*. Washington, DC: World Bank.

Ministry of Education, Youth and Sport.2014. Public Information Letter 03 and 436, issued on 31 January 2014.

Ministry of Health. 2008. *Community Participation Policy for Health.* Phnom Penh: MOH.

Norman, David J. 2014. “From Shouting to Counting: Civil Society and Good Governance Reform in Cambodia.” *Pacific Review* 27(2): 241-264.

Peruzotti, Enrique, and Catalina Smulovitz. 2006. *Enforcing the Rule of Law: Social Accountability in the New Latin American Democracies.* Pittsburgh, PA: University of Pittsburgh Press.

Rodan, Garry, and Caroline Hughes. 2012. “Ideological Coalitions and the International Promotion of Social Accountability: The Philippines and Cambodia Compared.” *International Studies Quarterly* 56:367-380.

World Bank. 2013. *Voice, Choice and Decision 2: A Study of Local Basic Service Delivery in Cambodia.* Research Working Paper 82654. Washington, DC: World Bank and Asia Foundation.